ក

មាតិកា

I~ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៣-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦៥ ស្តីពីវិសោធនកម្មមាត្រា ៤ មាត្រា ១០ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី 0៤ ខែ កញ្ញា ឆ្នាំ ២000 ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ៣៨០១

១៣-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **លី វិន** (LI WEN) ជនជាតិចិន សញ្ជាតិចិន កើតនៅ Tiangsu ប្រទេសចិន ៣៨០៤

១៣-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី ឈុនខ្វៃ** (LI CHUN KWAI) ជនជាតិចិន សញ្ជាតិចិន កើតនៅ ក្វាងដុង ប្រទេសចិន ៣៨០៥

១៣-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦៨ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ ជូនឧត្តមសេនីយ៍ត្រី **ម៉ុន នី** ជានាយទាហានជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ ៣៨០៦

១៤-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៧៦ ស្តីពីការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈជូនសព នាយទាហានជាន់ខ្ពស់ ចំនួន 0៥ រូប ៣៨០៧

II~រាជរដ្ឋាភិបាល

១~អនុក្រឹត្យ

១៧-៦-២០០៥ -អនុក្រឹត្យលេខ ៨៣អនក្រ.បក ស្តីពីក្រមសីលធមិសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ៣៨០៨

២២-៦-២០០៥ -អនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៨២១

១៦-៦-២០០៥ -អនុក្រឹត្យលេខ ៥១១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៨២៣

១៦-៦-២០០៥ -អនុក្រឹត្យលេខ ៥១២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣៨២៥

១៦-៦-២០០៥ -អនុក្រឹត្យលេខ ៥១៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣៨២៦

១៧-៦-២០០៥	-អនុក្រឹត្យលេខ ៥១៤ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសកិច្ចការព្រំដែន	៣៨៣១
១៧-៦-២០០៥	-អនុក្រឹត្យលេខ ៥១៥ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង	៣៨៣៤
២១-៦-២០០៥	-អនុក្រឹត្យលេខ ៥១៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៣៨៣៧
២១-៦-២០០៥	-អនុក្រឹត្យលេខ ៥១៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៣៨៣៨
២១-៦-២០០៥	-អនុក្រឹត្យលេខ ៥១៨ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា	៣៨៣៩
២១-៦-២០០៥	-អនុក្រឹត្យលេខ ៥១៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	៣៨៤១
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២០ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ក្នុងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល	៣៨៤២
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២១ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត	៣៨៤៣
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៣៨៤៥
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២៣ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៨៤៧
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២៤ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៨៤៨
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២៥ អនក្រ.តត ស្តីពីការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៨៤៩
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២៦ អនក្រ.តត ស្តីពីការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៨៥១
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២៧ អនក្រ.តត ស្តីពីការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៨៥៣
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២៨ អនក្រ.តត ស្តីពីការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៨៥៥
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥២៩ អនក្រ.តត ស្តីពីការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៨៥៧
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥៣០អនក្រ.តត ស្តីពីការផ្ទេរ និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៣៨៥៩
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥៣១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	៣៨៦១
២២-៦-២០០៥	-អនុក្រឹត្យលេខ ៥៣២ អនក្រ.តត ស្តីពីការជូនមេដាយការងារ	៣៨៦២

២២-៦-២០០៥ -អនុក្រឹត្យលេខ ៥៣៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៩០៤

២២-៦-២០០៥ -អនុក្រឹត្យលេខ ៥៣៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣៩០៥

២២-៦-២០០៥ -អនុក្រឹត្យលេខ ៥៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៩១៣

២២-៦-២០០៥ -អនុក្រឹត្យលេខ ៥៣៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៩១៥

២២-៦-២០០៥ -អនុក្រឹត្យលេខ ៥៣៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៣៩១៧

២២-៦-២០០៥ -អនុក្រឹត្យលេខ ៥៣៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៩១៩

២២-៦-២០០៥ -អនុក្រឹត្យលេខ ៥៣៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៩២០

III_ការងារបណ្តាក្រសួង

១_លិខិតរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៧-៦-២០០៥ -ប្រកាសលេខ ២៩៨ សហវ ស្តីពីការអនុវត្តន៍អាករលើតម្លៃបន្ថែមចំពោះឧស្សាហកម្មគាំទ្រ ឬអ្នកចុះកិច្ចសន្យា ដែលធ្វើការផ្គត់ផ្គង់ផលិតផលឬសេវា សម្រាប់បម្រើឱ្យការនាំចេញរបស់ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មវាយនភ័ណ្ឌ និងឧស្សាហកម្មផលិតស្បែកជើង ៣៩២១

១៧-៦-២០០៥ -ប្រកាសលេខ ៣០២ សហវ.ប្រក.៣ជ ស្តីពីរយៈពេលលើកលែងលើប្រាក់ចំណេញបន្ត ២ ឆ្នាំ ជូនក្រុមហ៊ុនវិនិយោគផ្នែកវាយនភ័ណ្ឌបំរើឱ្យការនាំចេញ ៣៩២៥

២_លិខិតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០១-៦-២០០៥ -លិខិតលេខ ១២៥៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ុនម៉ែត អ៊ិនធើប្រាយ លីមីធីត** ៣៩២៧

០១-៦-២០០៥ -លិខិតលេខ ១២៥៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ដួង សាន ខនស្ត្រាក់សិន & ត្រេឌីង** ៣៩២៩

០១-៦-២០០៥ -លិខិតលេខ ១២៦១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **មេកហ្គូដ អ៊ិនធើណេសិនណល ខប** ៣៩៣១

០២-៦-២០០៥ -លិខិតលេខ ១២៦៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អិកស៊ីឡិន ស៊ូតើ លីមីធីត** ៣៩៣៣

០២-៦-២០០៥ -លិខិតលេខ ១២៧១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **នាយណា ហ្វូវីន អ៊ិនធើណេសិនណល អ៊ិនវេសមេន ភ្នំពេញ ម៉ាញូនីខ** ៣៩៣៥

០២-៦-២០០៥ -លិខិតលេខ ១២៧២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ប៉េត្រូ ខេមឌីន អ៊ិនទែសមេន ៣៩៣៧

០២-៦-២០០៥ -លិខិតលេខ ១២៧៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អ៊ិនធើណេសិនណល ហ្វ្រេត ឡូជីស្ទីក ៣៩៣៩

០២-៦-២០០៥ -លិខិតលេខ ១២៧៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ប៉េភ្កុល គ្រុប ៣៩៤១

០២-៦-២០០៥ -លិខិតលេខ ១២៧៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ចឺជូឃា ហ្វេនេ គ្រេដ (ខេមបូឌា) ៣៩៤៣

០៩-៦-២០០៥ -លិខិតលេខ ១៣៣៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អ៊ី អិល ខេ អ៊ិនជីនារីង សឺវីស ៣៩៤៥

១០-៦-២០០៥ -លិខិតលេខ ១៣៤១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ឃ្លីកស៊ូ (ខេមបូឌា) ៣៩៤៧

១០-៦-២០០៥ -លិខិតលេខ ១៣៤២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
សេនចូទ (ខេមបូឌា) ៣៩៤៨

១០-៦-២០០៥ -លិខិតលេខ ១៣៤៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ឱមស៊ូវ៉ា ៣៩៥០

១០-៦-២០០៥ -លិខិតលេខ ១៣៤៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស៊ូឡារីស អ៊ិនធើណេសិនណល ៣៩៥២

១០-៦-២០០៥ -លិខិតលេខ ១៣៤៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស្តារលី ខមភេនី (យូ.អេស.អេ) អិលធីឌី ៣៩៥៤

១០-៦-២០០៥ -លិខិតលេខ ១៣៤៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អ.អេស.ស៊ី គ្រុប ៣៩៥៦

១៣-៦-២០០៥ -លិខិតលេខ ១៣៥០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
(ខេមបូឌា) ហ៊ីង អ៊ុយ ៣៩៥៨

១៣-៦-២០០៥ -លិខិតលេខ ១៣៥១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
សិរីសោភ័ណមានជ័យ អ៊ីមផត អិចផត ៣៩៦០

១៣-៦-២០០៥ -លិខិតលេខ ១៣៥២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ស្តារ ផ្លាហ្សា ហូថេល ៣៩៦២

១៣-៦-២០០៥ -លិខិតលេខ ១៣៥៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខេ.ស៊ី & អឹម ឌីវេឡុបមេន** ៣៩៦៤

១៣-៦-២០០៥ -លិខិតលេខ ១៣៥៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អានជីន (ខេមបូឌា) អ៊ិនវេសមេន ខមភេនី** ៣៩៦៦

១៣-៦-២០០៥ -លិខិតលេខ ១៣៥៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **មីរៀល អង្គរ** ៣៩៦៨

១៣-៦-២០០៥ -លិខិតលេខ ១៣៥៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខូលប៊ីន អេនើជី (ខេមបូឌា) លីមីធីត** ៣៩៧០

២២-៦-២០០៥ -ប្រកាសលេខ ១៩១ MOC/SM 2005 ស្តីពីការធ្វើប្រតិភូកម្មជូនមន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ៣៩៧២

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៦៥

ស្តីពី

វិសោធនកម្មមាត្រា ៤, មាត្រា ១០ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ

នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០

ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង

សង្គ្រោះជនពិការដោយសារមីន

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពហោភាស កម្ពុជឯករាជ រដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសបន្ទាប់

មាត្រា មួយ :

មាត្រា ៤. មាត្រា ១០. មាត្រា១១ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើត អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ត្រូវធ្វើវិសោធនកម្មដូចតទៅ៖

មាត្រា ៤ ថ្មី : អ.ក.ត.ម.ស.ព.ម. មានសមាសភាព ដូចតទៅ:

- សម្តេចនាយករដ្ឋមន្ត្រី ជាប្រធាន
- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន ទី១
- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន ទី២
- ឥស្សរៈជនជាន់ខ្ពស់ ១ រូប ជាអគ្គលេខាធិការ
- តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
- តំណាងក្រសួងមហាផ្ទៃ ជាសមាជិក
- តំណាងក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាសមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក
- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ជាសមាជិក
- តំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ជាសមាជិក
- តំណាងគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន ជាសមាជិក
- តំណាងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាសមាជិក
- តំណាងអគ្គស្នងការនគរបាលជាតិ ជាសមាជិក
- តំណាងអាជ្ញាធរអប្សរា ជាសមាជិក
- ឥស្សរជនជាន់ខ្ពស់ជំនាញច្បាប់ ១ រូប ជាសមាជិក

អ.ក.ត.ម.ស.ព.ម. មានអគ្គលេខាធិការដ្ឋានជាសេនាធិការ ដែលដឹកនាំដោយអគ្គលេខាធិការ ០១ រូប ។

7/4

មាត្រា ១០ ថ្មី : សម្តេចនាយករដ្ឋមន្ត្រីអាចស្នើតែងតាំងអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់ជាជំនួយការអគ្គលេខាធិការ ។ អគ្គលេខាធិការរងនីមួយៗ ត្រូវទទួលបន្ទុកតាមការចាត់តាំងរបស់អគ្គលេខាធិការ ។

មាត្រា ១៣ ថ្មី : **អ.គ.គ.ម.ស.ព.ម.** មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ពីរ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា បី : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា បួន : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។៚

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧-០៥០៦.២៨១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

លេខ ... ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
... ស៊ាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមីជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី លី ទិន (LI WEN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៦៨ នៅ Tiangsu ប្រទេសចិន ។

មាត្រា ២ ៖ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

ពរស.០៥០៦.២៨២

លេខ ៖ ២៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាខ៊ី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **លី ឈុនឃៃ** (LI CHUN KWAI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៦០ នៅក្វាងដុង ប្រទេសចិន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ២៤៩. ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣កស.០៥០៦.២៨៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជូនឧត្តមសេនីយ៍ត្រី ម៉ុន នី អត្តលេខ ០០៤៣៧៨ ជានាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន.ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៩០៦.២៨៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

លេខ : ២៤៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាន់ តាន់

នស/រកត/០៦០៥/២៧៦

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈជូនសព ÷

ក. តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក

-ឧត្តមសេនីយ៍ទោ ឃួន ភីណុប អត្តលេខ ០០០១៩៩

ខ. តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី អ៊ឹ ទៀង អត្តលេខ ០០០២១២

២-ឧត្តមសេនីយ៍ត្រី ម៉ែន ផេង អត្តលេខ ០០០១៨៦

គ. តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក ឈឿង គុសល អត្តលេខ ០០៣៩០៣

២-វរសេនីយ៍ឯក អ៊ុក ម៉ៅ អត្តលេខ ០០៣៩២៦

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤៧-០៥០៦.២៩៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៥

លេខ ២៤៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ាវ គាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ក្រមសីលធម៌សម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស.រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ~~១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម~~ និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥

140181

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីបទប្បញ្ញត្តិស្តីពីក្រមសីលធម៌សម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត និងរាល់ប្រភេទសមាជិកដទៃទៀតរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ហៅកាត់ថា **វ.គ.ស.ក.** ដែលតទៅនេះហៅថា "**គណនេយ្យករជំនាញ**" ។ ក្រមសីលធម៌នេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើចំណុចសំខាន់ៗជាមូលដ្ឋាននៃក្រមសីលធម៌អន្តរជាតិ សម្រាប់គណនេយ្យករជំនាញរបស់សហព័ន្ធគណនេយ្យករអន្តរជាតិ ។

ពាក្យស័ព្ទបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ ÷

គណនេយ្យករជំនាញសំដៅដល់អ្នកប្រកបវិជ្ជាជីវៈសេរី ដែលមិនជាប់ពាក់ព័ន្ធនឹងកិច្ចសន្យាការងារជាមួយអង្គភាពដែលខ្លួនអនុវត្តភារកិច្ចក្នុងការ ÷

-កាន់បញ្ជីគណនេយ្យ

-ប្រមូលផ្តុំបញ្ជីគណនេយ្យ

-បើកបញ្ជីគណនេយ្យ

-បិទបញ្ជីគណនេយ្យ

-ត្រួតពិនិត្យបញ្ជីគណនេយ្យ

-ផ្ទៀងផ្ទាត់បញ្ជីគណនេយ្យ

-ធ្វើនិយតកម្មបញ្ជីគណនេយ្យ

-វាយតម្លៃ និងបញ្ចូលគ្នានូវបញ្ជីគណនេយ្យសហគ្រាស និងអង្គភាពនានា

-រៀបចំនូវរាល់វិធានគណនេយ្យ និងវិភាគតាមនីតិវិធីបច្ចេកទេសគណនេយ្យ នូវរបាយការណ៍ហិរញ្ញវត្ថុ និងស្ថានភាពប្រតិបត្តិការរបស់ក្រុមហ៊ុនស្របទៅតាមទិដ្ឋភាពទាំងឡាយ ក្នុងវិស័យសេដ្ឋកិច្ច គតិយុត្ត និងហិរញ្ញវត្ថុ

-រាយការណ៍ជាលាយលក្ខណ៍អក្សរពីការងាររបស់ខ្លួន ដោយមានចែងនូវសេចក្តីសង្កេត សេចក្តីសន្និដ្ឋាន និងសំណូមពរ ។

សវនករប្រតិស្រុត សំដៅដល់អ្នកដែលប្រកបវិជ្ជាជីវៈក្នុងនាម និងក្រោមការទទួលខុសត្រូវរបស់ខ្លួនផ្ទាល់ ដើម្បីបញ្ជាក់អំពីការទៀងទាត់ និងភាពស្មោះត្រង់នៃរបាយការណ៍ហិរញ្ញវត្ថុរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលសវនករប្រតិស្រុតនោះ អនុវត្តការងារសវនកម្មតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ឬតាមកិច្ចព្រមព្រៀង ។

គ្មានបុគ្គលណាអាចប្រកបវិជ្ជាជីវៈជាគណនេយ្យករជំនាញ និង ឬសវនករប្រតិស្រុតបានទេ ប្រសិនបើបុគ្គលនោះមិនបានចុះឈ្មោះក្នុងតារាងវិជ្ជាជីវៈគណនេយ្យករជំនាញរបស់ **វ.គ.ស.ក.** ។

មាត្រា ២.-

សិទ្ធិដែលបានប្រគល់ឱ្យ និងកាតព្វកិច្ចដែលត្រូវគោរពដោយគណនេយ្យករជំនាញ ដែលប្រកបវិជ្ជាជីវៈឯករាជ្យ ឬបម្រើការងារក្នុងផ្នែកពាណិជ្ជកម្ម ត្រូវកំណត់ដោយលម្អិតក្នុងក្រមកាតព្វកិច្ចនៃវិជ្ជាជីវៈ រៀបរៀងដោយ **វ.គ.ស.ក.** ។

ជំពូកទី ២
ផលប្រយោជន៍សាធារណៈ

មាត្រា ៣.-

គោលដៅចម្បងរបស់វិជ្ជាជីវៈគណនេយ្យ គឺការយល់ព្រមទទួលខុសត្រូវបំពេញតួនាទីរបស់ខ្លួន ក្នុងផលប្រយោជន៍សាធារណៈ ។ ដូច្នេះការទទួលខុសត្រូវរបស់គណនេយ្យករជំនាញ គឺមិនមែនត្រឹមតែបំពេញតាមតម្រូវការរបស់អតិថិជនណាមួយ ឬនិយោជករបស់ខ្លួនតែប៉ុណ្ណោះនោះឡើយ ។

មាត្រា ៤.-

ផលប្រយោជន៍សាធារណៈ ត្រូវបានចាត់ទុកជាផលប្រយោជន៍រួមរបស់សហគមន៍ប្រជាជន និងរបស់អង្គភាពដែលគណនេយ្យករជំនាញបម្រើការ ដោយរាប់បញ្ចូលទាំងអតិថិជន អ្នកផ្តល់ឥណទាន រដ្ឋអំណាច និយោជក និយោជិត វិនិយោគិន សហគមន៍ជំនួញ និងហិរញ្ញវត្ថុ និងអ្នកដទៃទៀតដែលពឹងផ្អែកលើការងាររបស់គណនេយ្យករជំនាញ ។

ជំពូកទី ៣
គោលការណ៍គ្រឹះ

មាត្រា ៥.-

គោលការណ៍គ្រឹះរួមមានភាពសុចរិត ភាពមិនលម្អៀង សមត្ថភាព និងការយកចិត្តទុកដាក់ខាងវិជ្ជាជីវៈ រក្សាការសម្ងាត់ និងចរិយាមារយាទក្នុងវិជ្ជាជីវៈ ។

ផ្នែកទី ១
ភាពសុចរិត

មាត្រា ៦.-

គោលការណ៍នៃភាពសុចរិត ជាភាពព្វកិច្ចដែលតម្រូវឱ្យគ្រប់គណនេយ្យករជំនាញគោរពតាម នៅក្នុងទំនាក់ទំនងវិជ្ជាជីវៈ និងកិច្ចការជំនួញឱ្យប្រកបដោយភាពស្មោះត្រង់ និងសុចរិត ។ ភាពសុចរិតសំដៅផងដែរលើភាពត្រឹមត្រូវក្នុងទំនាក់ទំនងកិច្ចការជំនួញ និងភាពទៀងត្រង់ ។

មាត្រា ៧.-

គណនេយ្យករជំនាញមិនត្រូវមានការពាក់ព័ន្ធទៅនឹងសេចក្ដីរាយការណ៍ របាយការណ៍ ការឆ្លើយឆ្លងព័ត៌មាន ឬ ព័ត៌មានផ្សេងៗទៀត ដែលគណនេយ្យករជំនាញមានការជឿជាក់ថាព័ត៌មាននោះ ÷

ក- មានបញ្ចូលសេចក្ដីរាយការណ៍មិនពិត ឬនាំឱ្យមានការភ័ន្តច្រឡំ ។

ខ- មានបញ្ចូលរបាយការណ៍ ឬព័ត៌មានដែលគ្មានការទទួលខុសត្រូវ ។

គ- មានរាយការណ៍ព័ត៌មានចាំបាច់ ប៉ុន្តែដោយមានការខ្វះខាត ឬដោយមិនច្បាស់លាស់ហើយការខ្វះខាតព័ត៌មាន ឬភាពមិនច្បាស់លាស់នោះនឹងបង្កឱ្យមានការភ័ន្តច្រឡំ ។

ផ្នែកទី ២
ភាពមិនលម្អៀង

មាត្រា ៨.-

គោលការណ៍នៃភាពមិនលម្អៀង ជាភាពព្វកិច្ចដែលតម្រូវឱ្យគ្រប់គណនេយ្យករជំនាញគោរពតាមនៅក្នុងការវិនិច្ឆ័យខាងវិជ្ជាជីវៈ ឬកិច្ចការជំនួញ ដោយមិនផ្អែកលើបុរេនិច្ឆ័យ ឬបុរេមតិ ទំនាស់ផលប្រយោជន៍ ឬឥទ្ធិពលពីអ្នក ដទៃឡើយ ។

មាត្រា ៩.-

គណនេយ្យករជំនាញ អាចជួបប្រទះស្ថានភាពដែលនាំអោយប៉ះពាល់ដល់ភាពមិនលម្អៀងរបស់ខ្លួន ។ នៅក្នុងការអនុវត្តជាក់ស្តែង គេមិនអាចកំណត់គ្រប់ករណីដែលនាំឱ្យប៉ះពាល់ដល់ភាពមិនលម្អៀងបានឡើយ ។ គណនេយ្យករជំនាញត្រូវចៀសវាងទំនាក់ទំនងដែលធ្វើឱ្យមានបុរេនិច្ឆ័យ ឬបុរេមតិ ឬឥទ្ធិពលពីអ្នកដទៃដែលអាចអោយប៉ះពាល់ ដល់ការវិនិច្ឆ័យខាងវិជ្ជាជីវៈរបស់ខ្លួន ។

ផ្នែកទី ៣
សមត្ថភាព និងការយកចិត្តទុកដាក់ខាងវិជ្ជាជីវៈ

មាត្រា ១០.-

គោលការណ៍នៃសមត្ថភាព និងការយកចិត្តទុកដាក់ខាងវិជ្ជាជីវៈ ជាកាតព្វកិច្ចដែលតម្រូវឱ្យគ្រប់គណនេយ្យករជំនាញ ÷

១- សម្រិតសម្រាំងចំណេះដឹងវិជ្ជាជីវៈ និងជំនាញក្នុងកម្រិតចាំបាច់ ដើម្បីធានាថាអតិថិជន ឬនិយោជក ទទួលបាននូវសេវាវិជ្ជាជីវៈប្រកបដោយសមត្ថភាពខ្ពស់ និងពេញលេញ ។

២- បំពេញមុខងារដោយយកចិត្តទុកដាក់ និងដោយអនុលោមទៅតាមស្តង់ដារបច្ចេកទេសដែលអាចអនុវត្តបាន និងស្តង់ដារនៃវិជ្ជាជីវៈនៅក្នុងរាល់ទំនាក់ទំនងវិជ្ជាជីវៈ និងកិច្ចការជំនួញ ។

មាត្រា ១១.-

សេវាវិជ្ជាជីវៈប្រកបដោយសមត្ថភាពខ្ពស់ តម្រូវឱ្យមានការវិនិច្ឆ័យម៉ឺងម៉ាត់នៅក្នុងការប្រើប្រាស់ចំណេះដឹង និង មុខជំនាញវិជ្ជាជីវៈក្នុងការផ្តល់សេវានោះ ។ សមត្ថភាពវិជ្ជាជីវៈអាចត្រូវបានចែកចេញជាពីរដំណាក់កាលដោយឡែកពីគ្នា គឺ ÷

១- ការសម្រេចបាននូវសមត្ថភាពវិជ្ជាជីវៈ ។

២- ការសម្រិតសម្រាំងសមត្ថភាពវិជ្ជាជីវៈ ។

មាត្រា ១២.-

ដើម្បីសម្រេចបាននូវសមត្ថភាពវិជ្ជាជីវៈ តម្រូវឱ្យមានជាសារវន្តនូវស្តង់ដារនៃការអប់រំចំណេះដឹងទូទៅខ្ពស់ គួបផ្សំជាមួយការអប់រំបន្ថែម ការបណ្តុះបណ្តាល និងការប្រលង ជាពិសេសក្នុងប្រធានបទដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈគណនេយ្យ ហើយនិងបទពិសោធន៍ក្នុងការងារ ប្រសិនជាអាចទទួលយកបាន ។ នេះគឺជាដំណើរការធម្មតា

ក្នុងការបណ្តុះបណ្តាលគណនេយ្យករជំនាញ ។ គណនេយ្យករជំនាញក៏ត្រូវចាត់វិធានការដើម្បីធានាថាសហការី ដែលប្រកបវិជ្ជាជីវៈក្រោមឱវាទរបស់ខ្លួនត្រូវតែបានទទួលការបណ្តុះបណ្តាលសមស្រប ។

មាត្រា ១៣.-

ការសម្រិតសម្រាំងសមត្ថភាពវិជ្ជាជីវៈ តម្រូវឱ្យគណនេយ្យករជំនាញបង្កើនការយល់ដឹងស្របទៅនឹងការវិវឌ្ឍផ្នែកបច្ចេកទេសនៃវិជ្ជាជីវៈគណនេយ្យ និងកិច្ចការជំនួញជាប់ជានិច្ច ។

មាត្រា ១៤.-

ការយកចិត្តទុកដាក់ ត្រូវរាប់បញ្ចូលទាំងការទទួលខុសត្រូវក្នុងការបំពេញភារកិច្ចឱ្យស្របទៅតាមការតម្រូវនៃការងារដែលបានប្រគល់ឱ្យប្រកបដោយភាពប្រុងប្រយ័ត្ន ភាពហ្មត់ចត់ និងគោរពតាមពេលវេលាកំណត់ ។

ផ្នែកទី ៤
ការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ

មាត្រា ១៥.-

គោលការណ៍នៃការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ជាកាតព្វកិច្ចដែលតម្រូវឱ្យគណនេយ្យករជំនាញ ចៀសវាងនូវ ÷

១- ការផ្សព្វផ្សាយដោយគ្មានការអនុញ្ញាតត្រឹមត្រូវ និងជាក់លាក់ចំពោះព័ត៌មានសម្ងាត់ដែលបានទទួលក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងវិជ្ជាជីវៈ និងកិច្ចការជំនួញ លើកលែងតែសិទ្ធិ ឬភារកិច្ចស្របច្បាប់ ឬសិទ្ធិឬភារកិច្ចវិជ្ជាជីវៈតម្រូវឱ្យធ្វើ ។

២- ការប្រើប្រាស់ព័ត៌មានសម្ងាត់ដែលបានទទួលក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងវិជ្ជាជីវៈ និងកិច្ចការជំនួញ សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍របស់តតិយជនណាមួយ ។

មាត្រា ១៦.-

គណនេយ្យករជំនាញត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ទោះបីជានៅក្នុងបរិស្ថានសង្គមក៏ដោយ ជាពិសេសក្នុងគ្រប់កាលៈទេសៈដូចជា ក្នុងទំនាក់ទំនងយូរអង្វែងជាមួយនឹងសមាគមអាជីវករ ឬទំនាក់ទំនងជាមួយសាច់ញាតិជិតនិងក្រុមគ្រួសារជិតដែលអាចនាំឱ្យបាត់បង់ការប្រុងប្រយ័ត្ន ធ្វើឱ្យធ្លាយការសម្ងាត់នៃវិជ្ជាជីវៈទាំងមិនដឹងខ្លួន ។

មាត្រា ១៧.-

គណនេយ្យករជំនាញក៏ត្រូវរក្សាផងដែរនូវការសម្ងាត់នៃវិជ្ជាជីវៈ ចំពោះព័ត៌មានដែលបានទទួលពីអតិថិជនដែលអាចក្លាយទៅជាអតិថិជន ឬនិយោជករបស់ខ្លួន ។

មាត្រា ១៨.-

គណនេយ្យករជំនាញត្រូវចាត់វាលវិធានការសមស្របដើម្បីធានាថា បុគ្គលិកក្រោមឱវាទរបស់ខ្លួនផ្ទាល់ និងបុគ្គលដែលបានសហការ និងផ្តល់យោបល់ក្នុងការងាររបស់ខ្លួន គោរពបានតាមភារកិច្ចរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។

មាត្រា ១៩.-

គណនេយ្យករជំនាញត្រូវបន្តគោរពតាមគោលការណ៍រក្សាការសម្ងាត់នៃវិជ្ជាជីវៈ ទោះបីខ្លួនបានបញ្ចប់ទំនាក់ទំនងជាមួយនឹងអតិថិជន ឬនិយោជកក៏ដោយ ។ នៅពេលដែលគណនេយ្យករជំនាញផ្លាស់ប្តូរការងារ ឬទទួលអតិថិជនថ្មីៗទៀត គេមានសិទ្ធិប្រើប្រាស់បទពិសោធន៍ដែលបានទទួលពីសកម្មភាពមុន ។ ប៉ុន្តែគណនេយ្យករជំនាញមិនត្រូវប្រើប្រាស់ ឬផ្សព្វផ្សាយព័ត៌មានសម្ងាត់ណាមួយទោះបីជាព័ត៌មាននោះទទួលបានដោយសារទំនាក់ទំនងក្នុងវិជ្ជាជីវៈ ឬកិច្ចការជំនួញក៏ដោយ ។

មាត្រា ២០.-

កាលៈទេសៈដែលតម្រូវឱ្យគណនេយ្យករជំនាញបង្ហាញព័ត៌មានសម្ងាត់នៃវិជ្ជាជីវៈ ឬពេលវេលាដែលសមស្រប ដើម្បីបង្ហាញព័ត៌មានមានដូចខាងក្រោម ÷

១- ច្បាប់បានអនុញ្ញាត ឬក៏អតិថិជន ឬក៏និយោជក បានអនុញ្ញាតឱ្យបង្ហាញព័ត៌មាន ។

២- ការតម្រូវដោយច្បាប់ អោយបង្ហាញព័ត៌មានដូចតទៅ ÷

-ការផ្តល់ឯកសារ ឬការផ្តល់ភស្តុតាងផ្សេងៗទៀត នៅក្នុងដំណើរការនៃនីតិវិធីតុលាការ

-ការផ្តល់ព័ត៌មានទៅឱ្យអាជ្ញាធរសាធារណៈមានសមត្ថកិច្ច នៅពេលបានជួបប្រទះអំពើល្មើសច្បាប់ ។

៣-នៅពេលគ្មានបម្រាមច្បាស់ ហើយគណនេយ្យករជំនាញមានភារកិច្ច ឬសិទ្ធិដើម្បីបង្ហាញព័ត៌មាននោះ ក្នុងគោលដៅ ÷

- អនុវត្តទៅតាមស្តង់ដារបច្ចេកទេស និងការតម្រូវនៃក្រមសីលធម៌
- ការពារផលប្រយោជន៍វិជ្ជាជីវៈរបស់គណនេយ្យករជំនាញនៅក្នុងនីតិវិធីតុលាការ
- អនុវត្តតាមការពិនិត្យគុណភាពពីក្រុមសមាជិក ឬ **ទ.គ.ស.ក.** ឬ

- ឆ្លើយតបទៅនឹងការសាកសួរ ឬការស៊ើបអង្កេតតាមផ្លូវការរបស់ក្រុមសមាជិក ឬអង្គភាពត្រួតពិនិត្យ ។

មាត្រា ២១.-

នៅក្នុងការសម្រេច ថាតើគួរគប្បីបង្ហាញព័ត៌មានសម្ងាត់នេះដែរ ឬអត់នោះ គណនេយ្យករជំនាញត្រូវពិចារណាលើចំណុចដូចខាងក្រោម ៖

១- នៅពេលអតិថិជន ឬនិយោជកអនុញ្ញាតឱ្យបង្ហាញព័ត៌មាន ថាតើផលប្រយោជន៍របស់ភាគីទាំងអស់អាចប៉ះពាល់ ឬខូចខាតដែរ ឬទេរួមទាំងផលប្រយោជន៍របស់តតិយជនផង ។

២- តើព័ត៌មានដែលពាក់ព័ន្ធទាំងអស់មានលក្ខណៈត្រូវបានគេដឹង ឬមានអំណះអំណាងដែរឬទេ ។ ក្នុងករណីដែលស្ថានភាពពុំទាន់មានអំណះអំណាងច្បាស់លាស់ ឬពុំមានព័ត៌មានគ្រប់គ្រាន់ ឬសេចក្តីសន្និដ្ឋានពុំទាន់មានអំណះអំណាង គណនេយ្យករជំនាញត្រូវធ្វើសេចក្តីវិនិច្ឆ័យទៅតាមវិជ្ជាជីវៈរបស់ខ្លួន ដើម្បីសម្រេចប្រភេទនៃការបង្ហាញដែលត្រូវធ្វើ ។

៣- មធ្យោបាយដែលបានរំពឹងទុកដើម្បីផ្តល់ព័ត៌មាន ទន្ទឹមនឹងបុគ្គលដែលត្រូវទទួលព័ត៌មាននោះ ជាពិសេសគណនេយ្យករជំនាញត្រូវប្រាកដថា ភាគីអ្នកទទួលព័ត៌មានពិតជាអ្នកមានសិទ្ធិទទួលត្រឹមត្រូវ ។

ផ្នែកទី ៥
ចរិយាមារយាទក្នុងវិជ្ជាជីវៈ

មាត្រា ២២.-

គោលការណ៍នៃចរិយាមារយាទក្នុងវិជ្ជាជីវៈ ជាកាតព្វកិច្ចដែលតម្រូវឱ្យគណនេយ្យករជំនាញគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ហើយចៀសវាងអំពើទាំងឡាយដែលអាចធ្វើឱ្យអាប់ឱនដល់វិជ្ជាជីវៈរបស់ខ្លួន ។ គោលការណ៍នេះសំដៅផងដែរចំពោះទង្វើទាំងឡាយណា ដែលអាចធ្វើឱ្យតតិយជនមានការយល់ និងព័ត៌មានគ្រប់គ្រាន់អាចសន្និដ្ឋានថា ទង្វើនោះមានផលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់វិជ្ជាជីវៈគណនេយ្យករជំនាញ ។

មាត្រា ២៣.-

ក្នុងការផ្សាយពាណិជ្ជកម្មអំពីអត្តសញ្ញាណ និងមុខរបររបស់ខ្លួន គណនេយ្យករជំនាញមិនត្រូវបង្កបញ្ហាធ្វើឱ្យអាប់ឱនដល់វិជ្ជាជីវៈគណនេយ្យករជំនាញឡើយ ។ គណនេយ្យករជំនាញត្រូវមានភាពស្មោះត្រង់ និងភាពទៀងត្រង់ ហើយមិនត្រូវ ៖

១- ធ្វើការបំផ្លើសលើសេវារបស់ខ្លួន គុណវុឌ្ឍិរបស់ខ្លួន ឬបទពិសោធន៍ដែលខ្លួនបានទទួល ។

២- ឬធ្វើការរ៉ាយរ៉ាប់ដោយបញ្ចិតបញ្ចៀងនូវពាក្យសំដីមិនគប្បី ឬធ្វើការប្រៀបធៀបយោងទៅការងាររបស់អ្នកដទៃដោយគ្មានអ្វីជាសម្អាង ។

ជំពូកទី៤
ការគម្រាមកំហែង និងវិធីការពារ

មាត្រា ២៤.-

ការគោរព និងអនុវត្តតាមគោលការណ៍គ្រឹះអាចទទួលរងការគម្រាមកំហែងយ៉ាងខ្លាំងតាមរូបភាពជាច្រើន ។ ការគម្រាមកំហែងទាំងនោះ ត្រូវបានបែងចែកជាផ្នែកដូចខាងក្រោម ÷

១- ការគម្រាមកំហែងដោយសារផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចកើតឡើងដោយសារតែផលប្រយោជន៍ហិរញ្ញវត្ថុ ឬផលប្រយោជន៍ផ្សេងទៀតរបស់គណនេយ្យករជំនាញផ្ទាល់ខ្លួន ឬញាតិជិត ឬក្រុមគ្រួសារ ។

២- ការគម្រាមកំហែងពីស្វ័យត្រួតពិនិត្យឡើងវិញ ដែលអាចកើតឡើងនៅពេលវាយតម្លៃឡើងវិញនូវការវិនិច្ឆ័យកន្លងមកដោយគណនេយ្យករជំនាញណាម្នាក់ ដែលទទួលខុសត្រូវចំពោះការវិនិច្ឆ័យនេះ ។

៣- ការគម្រាមកំហែងពីការផ្តល់យោបល់របស់អ្នកដទៃ ដែលអាចកើតមានឡើងនៅពេលដែលគណនេយ្យករជំនាញ ធ្វើការជម្រុញគោលជំហររបស់ខ្លួន ឬមតិយោបល់ដល់ចំណុចណាមួយដែលអាចធ្វើអោយប៉ះពាល់ដល់ភាពមិនលម្អៀងរបស់ខ្លួន ។

៤- ការគម្រាមកំហែងដោយសារមនោសញ្ចេតនា ដែលអាចកើតមានឡើងដោយសារទំនាក់ទំនងជិតស្និទ្ធគឺនៅពេលដែលគណនេយ្យករជំនាញមានសមានចិត្តគិតគូរដល់ផលប្រយោជន៍អ្នកដទៃ ។

៥- ការគម្រាមកំហែងដោយការបំភិតបំភ័យ ដែលអាចកើតមានឡើងនៅពេលគណនេយ្យករជំនាញត្រូវបានគេបំភ័យ ឬយល់ថាគេបានបំភ័យ ហើយមិនអាចបំពេញការងាររបស់ខ្លួនបានដោយគ្មានលម្អៀង ។

មាត្រា ២៥.-

វិធីការពារដែលអាចលុបបំបាត់ ឬកាត់បន្ថយការគម្រាមកំហែងដល់កម្រិតមួយដែលទទួលយកបាន ត្រូវបានបែងចែកចេញជាពីរប្រភេទសំខាន់ៗ ÷

១- វិធីការពារដែលបង្កើតឡើងដោយ វ.គ.ស.ក. ដោយច្បាប់ ឬដោយលិខិតបទដ្ឋានផ្សេងៗ ។

២- វិធីការពារនៅក្នុងបរិស្ថានការងារ ។

មាត្រា ២៦.-

វិធីការពារបង្កើតឡើងដោយ **ទ.គ.ស.ក.** ដោយច្បាប់ ឬលិខិតបទដ្ឋានមានជាអាទិ៍÷

១-ការតម្រូវខាងការបណ្តុះបណ្តាលអប់រំ និងបទពិសោធន៍ ដើម្បីប្រកបវិជ្ជាជីវៈជាគណនេយ្យករជំនាញ ។

២- ការតម្រូវជាបន្តបន្ទាប់លើការបង្កើនចំណេះដឹងវិជ្ជាជីវៈគណនេយ្យករជំនាញ ។

៣- លិខិតបទដ្ឋានស្តីពីអភិបាលកិច្ចសហគ្រាស ។

៤- ស្តង់ដាវិជ្ជាជីវៈគណនេយ្យករជំនាញ ។

៥- នីតិវិធីត្រួតពិនិត្យដែលកំណត់ដោយ **ទ.គ.ស.ក.** ឬដោយច្បាប់ និងនីតិវិធីខាងវិន័យ ។

៦- ការត្រួតពិនិត្យឯករាជ្យដោយតតិយជន ដែលច្បាប់បានផ្តល់អំណាចឱ្យទៅលើរបាយការណ៍ ការឆ្លងឆ្លើយព័ត៌មាន ឬព័ត៌មានដែលរៀបចំដោយគណនេយ្យករជំនាញ ។

មាត្រា ២៧.-

វិធីការពារមួយចំនួនអាចបង្កើនលទ្ធភាពរកឃើញ ឬទប់ស្កាត់សកម្មភាពអសីលធម៌ ។ វិធីការពារខ្លះត្រូវបានបង្កើតដោយ **ទ.គ.ស.ក.** ច្បាប់ លិខិតបទដ្ឋាន ឬនិយោជក ហើយមានជាអាទិ៍÷

១- ប្រព័ន្ធទទួលពាក្យបណ្តឹងដែលរៀបចំបានល្អ និងមានប្រសិទ្ធភាព និងដែលបានបង្កើតឡើងដោយនិយោជក ឬ **ទ.គ.ស.ក.** ឬអង្គភាពត្រួតពិនិត្យណាមួយដែលផ្តល់លទ្ធភាពដល់សហការី និយោជក និងសាធារណជន លើកឡើងពីអំពើអវិជ្ជា ឬសកម្មភាពអសីលធម៌ ។

២- ភារកិច្ចដែលកំណត់យ៉ាងច្បាស់លាស់
ដើម្បីរាយការណ៍អំពីការរំលោភលើការតម្រូវរបស់ក្រមសីល ធម៌ ។

មាត្រា ២៨.-

លក្ខណៈនៃវិធីការពារដែលត្រូវយកមកអនុវត្តមានច្រើនសណ្ឋានខុសៗគ្នា អាស្រ័យទៅលើកាលៈទេសៈ ។ ក្នុងការធ្វើការវិនិច្ឆ័យ គណនេយ្យករជំនាញគួរពិចារណាថាតតិយជនណាមួយដែលមានវិចារណញ្ញាណ ដឹងការពិត និងមានការយល់ដឹងអំពីព័ត៌មានពាក់ព័ន្ធនានា មុខជានឹងអាចសន្និដ្ឋានបានថាការគម្រាមកំហែង និងស្ថានភាពនៃវិធីការពារនោះមិនអាចទទួលយកបាន ឬមិនបាននោះហើយ ។

ជំពូកទី ៥
ដំណោះស្រាយវិវាទក្រមសីលធម៌

មាត្រា ២៩.-

ក្នុងការអនុវត្តតាមស្តង់ដារក្រមសីលធម៌ គណនេយ្យករជំនាញអាចជួបប្រទះបញ្ហាមួយចំនួនដែលកើតឡើងនៅជុំវិញការដោះស្រាយវិវាទ ឬទំនាស់ផ្ទៃក្នុងក្រមសីលធម៌នេះ ។ នៅពេលជួបប្រទះបញ្ហាបែបនោះ គណនេយ្យករជំនាញត្រូវអនុវត្តតាមគោលនយោបាយរបស់ក្រុមហ៊ុនខ្លួន អង្គភាពដែលខ្លួនបម្រើការ ឬ **វ.គ.ស.ក.** ដើម្បីព្យាយាម និងដោះស្រាយវិវាទនោះ ។

មាត្រា ៣០.-

នៅពេលចាប់ផ្តើមដំណើរការដើម្បីដោះស្រាយវិវាទជាផ្លូវការក្តី ឬក្រៅផ្លូវការក្តី គណនេយ្យករជំនាញត្រូវពិចារណាទៅលើចំណុចណាមួយដូចខាងក្រោម ឬចំណុចទាំងអស់រួមគ្នា ដើម្បីដោះស្រាយវិវាទនោះ គឺ ÷

១- ព្រឹត្តិការណ៍ដែលពាក់ព័ន្ធ ។

២- បញ្ហាក្រមសីលធម៌ដែលពាក់ព័ន្ធ ។

៣- គោលការណ៍គ្រឹះដែលមានការពាក់ព័ន្ធទៅនឹងបញ្ហានោះ ។

៤- នីតិវិធីផ្ទៃក្នុងដែលបានបង្កើតឡើងក្នុងអង្គភាពដែលខ្លួនបម្រើការងារ ។

៥- វិធានការជំនួសផ្សេងទៀត ។

បន្ទាប់ពីបានពិចារណាទៅលើបញ្ហាទាំងនេះ គណនេយ្យករជំនាញគួរតែកំណត់វិធានការល្អបំផុតណាមួយដែលស្របទៅនឹងគោលការណ៍គ្រឹះ ។ គណនេយ្យករជំនាញគប្បីថ្លឹងថ្លែងផងដែរពីផលវិបាកនៃដំណោះស្រាយដែលបានជ្រើសរើស ។ ប្រសិនបើបញ្ហានេះនៅតែមិនអាចដោះស្រាយបាន គណនេយ្យករជំនាញត្រូវរកអ្នកមានឋានៈសមស្របនៅក្នុងក្រុមហ៊ុនរបស់ខ្លួន ឬអង្គភាពដែលខ្លួនបម្រើការងារ ដើម្បីជួយរកដំណោះស្រាយ ។

មាត្រា ៣១.-

នៅពេលបញ្ហាវិវាទនោះកើតឡើងជាមួយគណនេយ្យករជំនាញ ឬនៅក្នុងអង្គភាពដែលកំពុងធ្វើសវនកម្មនោះ គណនេយ្យករជំនាញគួរតែសុំជួបជាមួយនឹងគណៈកម្មាធិការសវនកម្ម ឬគណៈកម្មាធិការផ្សេងទៀតដែលទទួលខុសត្រូវក្នុងអភិបាលកិច្ចអង្គភាពនោះ ។ ដើម្បីជាប្រយោជន៍របស់ខ្លួន គណនេយ្យករជំនាញត្រូវធ្វើការកត់ត្រាធាតុពិតនៃបញ្ហាភាពពិស្តារនៃការពិភាក្សាណាមួយ ឬសេចក្តីសម្រេចណាមួយដែលទាក់ទងទៅនឹងបញ្ហានោះ ។

មាត្រា ៣២.-

ប្រសិនបើវិវាទមានសារៈសំខាន់មិនអាចដោះស្រាយបាន គណនេយ្យករជំនាញអាចធ្វើការពិគ្រោះ ឬប្រឹក្សាយោបល់ជាមួយនឹង **វ.គ.ស.ក.** ដែលអាចផ្តល់ការណែនាំទៅលើបញ្ហាក្រមសីលធម៌នេះ ដោយមិនបំពានទៅលើគោលការណ៍រក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។ គណនេយ្យករជំនាញក៏អាចពិគ្រោះយោបល់ជាមួយអ្នកប្រកបវិជ្ជាជីវៈច្បាប់ផងដែរ ។

មាត្រា ៣៣.-

ក្នុងករណីដែលគណនេយ្យករជំនាញបានព្យាយាមរកដំណោះស្រាយគ្រប់វិធីហើយ ប៉ុន្តែបញ្ហានៅតែមិនអាចដោះស្រាយបាននោះ គណនេយ្យករជំនាញគប្បីសុំដកខ្លួនចេញពីបញ្ហានេះតាមលទ្ធភាពដែលអាចធ្វើទៅបាន ។ ក្នុងកាលៈទេសៈបែបនេះ គណនេយ្យករជំនាញត្រូវពិចារណាផងដែរអំពីភាពសមស្របនៃការលាឈប់ពីភារកិច្ច ចាត់តាំង ឬលាឈប់ពីការងារជាក់លាក់មួយ ឬលាចេញទាំងស្រុងពីភារកិច្ចចាត់តាំងផង និងពីក្រុមហ៊ុនគណនេយ្យករជំនាញ ឬអង្គភាពដែលខ្លួនបម្រើការងារឱ្យនោះទៀតផង ។

ជំពូកទី ៦
ទណ្ឌកម្មខាងវិន័យ

មាត្រា ៣៤.-

អនុលោមទៅតាមមាត្រា៧ នៃអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ទណ្ឌកម្មខាងវិន័យត្រូវបាន អនុវត្តចំពោះគណនេយ្យករជំនាញណាដែលប្រព្រឹត្តល្មើសនឹងវិធាននៃវិជ្ជាជីវៈ ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់សីលធម៌ ឬកិត្តិយសវិជ្ជាជីវៈគណនេយ្យករជំនាញ ទោះបីគិតឃើញថាការប្រព្រឹត្តនោះក្រៅពីការប្រកបវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ។ ក្រុមប្រឹក្សាវិន័យរបស់ **វ.គ.ស.ក.** មានសមត្ថកិច្ចក្នុងការវិនិច្ឆ័យវិវាទពាក់ព័ន្ធនឹងសកម្មភាពរបស់គណនេយ្យករជំនាញ ។

មាត្រា ៣៥.-

សាមីជនគ្រប់រូបអាចប្តឹងទៅក្រុមប្រឹក្សាវិន័យ **វ.គ.ស.ក.** ។ ការចោទប្រកាន់ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាភិបាល **វ.គ.ស.ក.** ខ្លួនឯងផ្ទាល់ ឬដោយមានពាក្យបណ្តឹងពីសមាជិក **វ.គ.ស.ក.** ឬដោយមានពាក្យបណ្តឹងពីតតិយជន ឬដោយមានពាក្យបណ្តឹងពីស្នងការរាជរដ្ឋាភិបាលនៅអម **វ.គ.ស.ក.** ។

ជំពូកទី ៧
អវសានប្បញ្ញត្តិ

មាត្រា ៣៦.-

បទប្បញ្ញត្តិនៃមាត្រាទាំងឡាយខាងលើក៏ត្រូវអនុវត្តចំពោះគ្រប់សវនករកម្ពុជាជាសមាជិកនៃ **វ.គ.ស.ក.** ផងដែរ ។

មាត្រា ៣៧.-

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រុមប្រឹក្សាជាតិគណនេយ្យ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣៨
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៤ អនក្រ - បក

អនុក្រឹត្យ

ស្តីពីការផ្ទេរតំណែងនាយកនាយកដ្ឋានថវិកា

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧, ចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤, ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០.ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១២០៤/ ០០២ .ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយចរន្តទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤០០ លានរៀល (បួនរយលានរៀលគត់) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយរៀបចំជួសជុលអាគារក្រហម និង អាគារចំនួន ៣ ខ្នង ទៀតដែលមានសភាពចាស់ទ្រុឌទ្រោម ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

កាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៥១១...អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៨៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ
- យោងតាមតម្រូវការការងាររបស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមានរាយនាមខាងក្រោម ៖

១_លោក ឡឹក ចណ្ណជន	អគ្គាធិការរង នៃអគ្គាធិការដ្ឋាន
២_លោក ឃួត ចាន់ធី	អគ្គាធិការរង នៃអគ្គាធិការដ្ឋាន
៣_លោក ចំនួ សុចណ្ណារ៉េត	អគ្គាធិការរង នៃអគ្គាធិការដ្ឋាន
៤_លោក កែវ សម្បត្តិ	អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
៥_លោក ហេង សួរ	អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
៦_លោក ឌី សេរីរិទ្ធ	អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ

៧_លោក	សុខ ម៉ូរី	អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ
៨_លោក	ស៊ិន ចែឡាំ	អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និង វិជ្ជាជីវៈ
៩_លោក	គឹម ស៊ើន	អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និង វិជ្ជាជីវៈ
១០_លោក	ឆេត ណារី	អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និង វិជ្ជាជីវៈ
១១_លោក	ទី ស៊ីម៉ាណែត	ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
១២_លោក	ហាច ហ៊ាន	ប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក
១៣_លោក	ស៊ើង សរសុចិន្តា	ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និង នីតិកម្ម
១៤_លោក	ស្វាយ ទិចិត្រ	ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរដ្ឋ
១៥_លោក	ឃិន ចន្ថា	ប្រធាននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេទេស និង វិជ្ជាជីវៈ
១៦_លោក	ហែម ម៉ុននី	ប្រធាននាយកដ្ឋានមុខរបរ និង ហត្ថពលកម្ម
១៧_លោក	អ៊ិន ខេមរា	ប្រធាននាយកដ្ឋានអធិការកិច្ចការងារ
១៨_លោក	គុយ ឆេតជាភទ្ទុធ	ប្រធាននាយកដ្ឋានវិវាទការងារ
១៩_លោក	ទើង ហឿង	ប្រធាននាយកដ្ឋានការងារកុមារ
២០_លោក	ឡេង តុង	ប្រធាននាយកដ្ឋានពេទ្យការងារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥១២...អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

__មាត្រា ១__ : ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ ជូនភ្នាក់ងារ FBI ចំនួន ០២រូប និងភ្នាក់ងារសហព័ន្ធប៉ូលីសអូស្ត្រាលី ចំនួន ០១រូប ដែលបានចូលរួមសហការក្នុងកិច្ចប្រតិបត្តិការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ក្នុងការបង្ក្រាបករណី CFF និងករណីបង្ក្រាបបទល្មើសឆ្លងដែន ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :

១- លោក	**ROBERT H. CAHILL, JR.**	អនុព័ន្ធផ្នែកច្បាប់ FBI
២- លោក	**ROBERT A. BURKES**	ជំនួយការអនុព័ន្ធផ្នែកច្បាប់ FBI
៣- លោក	**Kenneth Gordon HARDING**	ភ្នាក់ងារសហព័ន្ធ ប៉ូលីសសហព័ន្ធអូស្ត្រាលី

__មាត្រា ២__ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០០៥

ហ៊ុន សែន

__កន្លែងទទួល :__

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥១៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ចំនួន ១៥០ នាក់ ដែលបានចុះបំពេញភារកិច្ចជួយក្នុងការងាររដ្ឋបាល និងការអភិវឌ្ឍន៍ គ្រប់ផ្នែកក្នុងស្រុកទ្រាំង ខេត្តតាកែវ ទទួលបានលទ្ធផល និងស្នាដៃធំ ៗ ជាច្រើន ដូចមានរាយនាមខាងក្រោមនេះ :

ក. មេដាយមាសការងារ :

១- ឯកឧត្តម **មិន ឃិន** អនុប្រធានអចិន្ត្រៃយ៍គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ
២- លោកជំទាវ **ខួន ឆួន** ទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី ១ រដ្ឋសភាជាតិ
៣- ឯកឧត្តម **ឌៀង សេង** អគ្គលេខា ធនាគារជាតិ នៃកម្ពុជា
៤- ឯកឧត្តម **ហង្ស សារឿន** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគ្រោះមហន្តរាយ
៥- ឯកឧត្តម **សេង លីមនៅ** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី
៦- ឯកឧត្តម **ហូ វិចិត្រ** អនុប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា នៃទីស្តីការគណៈរដ្ឋមន្ត្រី
៧- ឯកឧត្តម **ពៅ សាមី** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគ្រោះមហន្តរាយ
៨- ឯកឧត្តម **លី គីមសុខ** នាយកសាលាភូមិន្ទរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី
៩- ឯកឧត្តម **ភូ លីធុន្ឌ** អគ្គលេខាធិការ NIDA នៃទីស្តីការគណៈរដ្ឋមន្ត្រី
១០- ឯកឧត្តម **សុខុម គគចន្ទមុន្នី** អគ្គនាយក រ.អ.យ.ក នៃក្រសួងសាធារណការ និងដឹកជញ្ជូន
១១- ឯកឧត្តម **សយ សុខាន់** អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
១២- ឯកឧត្តម **ជា គាន** អគ្គលេខាធិការរង គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

១៣-ឯកឧត្តម	ជា	សុខុម	អគ្គលេខាធិការរងទី១ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ
១៤-ឯកឧត្តម	ញ៉ែម	ម៉ាលី	អគ្គលេខាធិការរង គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ
១៥-លោក	ខឹម	ពិសិដ្ឋ	សមាជិកក្រុមអ្នកសង្កេតការសេដ្ឋកិច្ច សង្គម ទីស្តីការគណៈរដ្ឋមន្ត្រី
១៦-លោក	វេង	ឈេង	អគ្គលេខាធិការ គណៈកម្មាធិការជាតិ ប្រជាជន និងការអភិវឌ្ឍន៍
១៧-លោក	ឆេង	ឯម	ប្រធានមន្ទីរវប្បធម៌ខេត្ត តាកែវ
១៨-លោក	កេត	ម៉ៅ	អភិបាលរងស្រុកទ្រាំង ខេត្តតាកែវ
១៩-លោក	ម៉ាន់	ម៉ូឈុយ	អនុប្រធាននាយកដ្ឋាន សាលាភូមិន្ទរដ្ឋបាល ទីស្តីការគណៈរដ្ឋមន្ត្រី
២០-លោក	ឆេព	ឆន	ប្រធាននាយកដ្ឋាន ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់
២១-លោក	ទេង	ឆន	អភិបាលរងស្រុកទ្រាំង ខេត្តតាកែវ
២២-លោក	សុខ	សារ៉ន	សមាជិកក្រុមប្រឹក្សាភិបាល រ.អ.យ.ក នៃក្រសួងសាធារណការនិងដឹកជញ្ជូន
២៣-លោក	ស៊ឹម	ឫទ្ធីសែន	ប្រធាននាយកដ្ឋាន នៃក្រសួងយុត្តិធម៌
២៤-លោក	ឃុយ	ហៀង	ប្រធាននាយកដ្ឋាន នៃទីស្តីការគណៈរដ្ឋមន្ត្រី
២៥-លោក	មុី	សារុន	អនុប្រធាននាយកដ្ឋាន នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
២៦-លោក	ធឿន	ម៉ៅ	ប្រធាននាយកដ្ឋានគ្រឿងឥស្សរិយយស នៃទីស្តីការគណៈរដ្ឋមន្ត្រី
២៧-លោក	ខៀវ	បញ្ញាវុឌ្ឍ	អនុប្រធាននាយកដ្ឋាន នៃក្រសួងធម្មការ និងសាសនា
២៨-លោក	ទឹម	សុន	អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ
២៩-លោក	ស្រី	នី	ប្រធានគយ ផែស្ងួត នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៣០-លោក	ហង្ស	គឹមហេង	មន្ត្រីគយ រដ្ឋាករខេត្តកំពត
៣១-លោក	ម៉ែន	យ៉ាន	ប្រធាននាយកដ្ឋាន គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ
៣២-លោក	គី	ឡុង	ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា
៣៣-លោក	សៀង	ឈុនទ្រី	អនុប្រធានទីចាត់ការគយ រដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៣៤-លោក	ឆន	ឈិន	អភិបាលស្រុកទ្រាំង ខេត្តតាកែវ

ខ. មេដាយស្ថាក់ការងារ :

១- លោក	ចំន្ទ	ចិន	មន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
២- លោក	នៀង	ម៉ាលី	អធិការ នៃអធិការដ្ឋាននគរបាលស្រុកទ្រាំង ខេត្តតាកែវ
៣- លោក	ពៅ	ពុធសីហា	អគ្គនាយករង នៃសហគ្រាសផលិតឱសថកម្ពុជា
៤- លោក	ម៉ុក	ឆាន់	អគ្គនាយករង នៃក្រសួងអប់រំ យុវជន និងកីឡា
៥- លោក	ហួត	សារឹម	អគ្គនាយករង នៃសហគ្រាសផលិតឱសថកម្ពុជា
៦- លោក	ជូ	យិនស៊ីម	អគ្គនាយករងបច្ចេកទេស នៃក្រសួងសុខាភិបាល
៧- លោក	ហង្ស	ឌី	អាជីវករសំណង់ ស្រុកទ្រាំង ខេត្តតាកែវ
៨- លោក	ជា	ហេង	ប្រធានការិយាល័យសាលាស្រុកទ្រាំង ខេត្តតាកែវ
៩- លោក	ហាក់	សុគឿន	មន្ត្រី នៃទូរទស្សន៍អប្សរា
១០-លោក	យ៉ឹម	ហ៊ន	ប្រធានការិយាល័យសាលាស្រុកទ្រាំង ខេត្តតាកែវ
១១-លោក	ស៊ុំ	ឈុំម៉ុន	អគ្គនាយករង រាជបណ្ឌិតសភា នៃទីស្តីការគណៈរដ្ឋមន្ត្រី
១២-លោក	ខួន	ស្រ៊ឹម	មន្ត្រី នៃស្នងការដ្ឋាននគរបាលខេត្តតាកែវ
១៣-លោក	ឌុច	ទិន	អនុប្រធាននាយកដ្ឋាន សាលាភូមិន្ទរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី
១៤-លោក	ម៉ៅ	គឹមថេង	ប្រធានការិយាល័យ សាលាភូមិន្ទរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី
១៥-លោក	ទេព	កុសល	ប្រធានការិយាល័យ សាលាភូមិន្ទរដ្ឋបាល នៃទីស្តីការគណៈរដ្ឋមន្ត្រី

១៦-លោក ទ្រាំ សុត ប្រធានការិយាល័យសាលាស្រុកទ្រាំង ខេត្តតាកែវ
១៧- លោក ហ៊ីង ធីរិទ្ធ ចៅក្រមតុលាការខេត្តស្ទឹងត្រែង
១៨- លោក សុខ សីលា ពាណិជ្ជកររាជធានីភ្នំពេញ
១៩- លោក ម៉ៅ ញឹម ប្រធានការិយាល័យ រ.អ.យ.ក នៃក្រសួងសាធារណការ និងដឹកជញ្ជូន
២០- លោក ហ៊ុយ រិទ្ធ នាយកក្បាលម៉ាស៊ីន និងទូរថភ្លើង នៃក្រសួងសាធារណការ និងដឹកជញ្ជូន
២១- លោក លន់ សុលីន ប្រធានតំបន់ រ.អ.យ.ក នៃក្រសួងសាធារណការ និងដឹកជញ្ជូន
២២- លោក សុខ វណ្ណា លេខាឯកឧត្តមអគ្គនាយក រ.អ.យ.ក នៃក្រសួងសាធារណការ និងដឹកជញ្ជូន
២៣- លោក ស៊ូ ផល្លី ប្រធានការិយាល័យ រ.អ.យ.ក នៃក្រសួងសាធារណការ និងដឹកជញ្ជូន
២៤- លោក ថោង ចន្ធូ ប្រធានការិយាល័យ រ.អ.យ.ក នៃក្រសួងសាធារណការ និងដឹកជញ្ជូន
២៥- លោក ធូ សារ៉ា នាយករងរដ្ឋបាល រ.អ.យ.ក នៃក្រសួងសាធារណការ និងដឹកជញ្ជូន
២៦- លោក រិត ចឿន នាយកអាជីវកម្ម រ.អ.យ.ក នៃក្រសួងសាធារណការ និងដឹកជញ្ជូន
២៧- លោក លី បូរិន នាយកផ្លូវ ស្ពាន អាគារ រ.អ.យ.ក នៃក្រសួងសាធារណការ និងដឹកជញ្ជូន
២៨- លោក សោ សុគីរ ប្រធានតុលាការរាជធានីភ្នំពេញ
២៩- លោក តាន់ សេណារ៉ុង ចៅក្រមតុលាការរាជធានីភ្នំពេញ
៣០- លោក លិន សីលា អនុប្រធាននាយកដ្ឋាន ក្រសួងយុត្តិធម៌
៣១- លោក ចាន់ គីស៊ាង ផ្នែកសីករងស្រុកទ្រាំង ខេត្តតាកែវ
៣២- លោក រំចេក សុធីរី អគ្គនាយករង នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
៣៣- លោក ស៊ិន ម៉ុនថាត ជំនួយការឯកឧត្តម ទា សុផា នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
៣៤- លោក កែវ ធិទុធ ប្រធានផ្នែកប្រឆាំងអំពើពុករលួយ នៃទីស្តីការគណៈរដ្ឋមន្ត្រី
៣៥- លោក អ៊ុំ សារឿន អនុប្រធានផ្សារសាមគ្គី ខណ្ឌទួលគោក រាជធានីភ្នំពេញ
៣៦- លោក ឯម ជួន បញ្ជាការរងអង្គភាពការពារថ្នាក់ដឹកនាំ ក្រសួងមហាផ្ទៃ
៣៧- លោក ស៊ិន ចំរើន ប្រធានមជ្ឈមណ្ឌលទូរស័ព្ទ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
៣៨- លោក ឡាយ ម៉ារីទ្ធ អគ្គនាយករង នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
៣៩- លោក នង គន្ធាវី ប្រធានការិយាល័យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤០- លោក ម៉ែន ស្រ៊ន ប្រធានឃ្លាំងសំភារៈ មន្ទីរពេទ្យព្រះកុសមៈ
៤១- លោក យ៉េម សិរៈ មន្ត្រីពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤២- លោក ហែម គិន មន្ត្រីពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤៣- លោក គាំ សុខុន ក្រសួងមហាផ្ទៃ
៤៤- លោក ហ៊ូ ហ៊ាន អនុប្រធានរតនាគារក្រុងភ្នំពេញ
៤៥- លោក គីម ឈួន មន្ត្រីពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
៤៦- លោក ឈុប សារ៉េត ប្រធានការិយាល័យ ន/បណ្តុះបណ្តាលនិងវិក្រឹតការ ក្រសួងមហាផ្ទៃ
